# កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រថ្នាក់ជាតិៈ ឧបករណ៍គន្លឹះដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រកបដោយសមធម៌

*ដោយលោក **Julian Hansen****

## ប្រវត្តិ

នៅកម្ពុជារហូតមកដល់ពេលថ្មីៗនេះ ការផ្តល់សេវា និងការធ្វើផែនការអភិវឌ្ឍន៍សំដៅកាត់បន្ថយភាពក្រីក្រ នៅមិនទាន់បានផ្តោតការយកចិត្តទុកដាក់គ្រប់គ្រាន់ទេ ទៅលើការកំណត់មុខសញ្ញាឱ្យបានច្បាស់លាស់ក្នុងការផ្តល់ជំនួយដល់ប្រជាពលរដ្ឋក្រីក្រ ។ កន្លងមកទោះជាមានការកំណត់មុខសញ្ញាបែបនេះក្តី ក៏ស្ថាប័ននីមួយៗបានរៀបចំ និងអនុវត្តនីតិវិធី និងលក្ខណៈវិនិច្ឆ័យរបស់ខ្លួនផ្ទាល់ ដើម្បីកំណត់ពីអ្នកត្រូវទទួលផលប្រយោជន៍ គឺបានន័យថា លទ្ធផលរកឃើញមិនអាចប្រៀបធៀបគ្នាបានទេ ហើយជាទូទៅក៏មិនដែលចែករំលែកទៅឱ្យអង្គការ ឬស្ថាប័នផ្សេងទៀតដែរ ។

នៅក្នុងវេទិកាថ្នាក់ជាតិមួយរៀបចំដោយក្រសួងផែនការ កាលពីខែកុម្ភៈ ២០០៥ មានការមូលមតិជាទូទៅស្តីពីតម្រូវការបង្កើតឱ្យមាននីតិវិធីស្តង់ដារថ្នាក់ជាតិមួយ សម្រាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ដើម្បីកាត់បន្ថយចំណាយរដ្ឋបាលទូទៅក្នុងការជ្រើសរើសក្រុមមុខសញ្ញា និងដើម្បីញ៉ាំងឱ្យការបែងចែកធនធានអភិវឌ្ឍន៍ដ៏កម្រ អាចធ្វើបានប្រកបដោយប្រសិទ្ធិភាពខ្ពស់ និងបានទៅដល់ដៃអ្នកដែលត្រូវការវាជាងគេបំផុត ។ ក្រុមការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រមួយ ដែលដឹកនាំដោយក្រសួងផែនការ និងមានជំនួយបច្ចេកទេសពីអង្គការសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ (GTZ) បានបង្កើតឡើងនៅខែមិថុនា ២០០៥ ជាអនុក្រុមមួយក្នុងក្រុមការងារបច្ចេកទេសស្តីពីផែនការ និងការកាត់បន្ថយភាពក្រីក្រ ។ សមាជិកក្រុមការងាររួមមានតំណាងមកពីក្រសួងជំនាញ ម្ចាស់ជំនួយ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា ។ ក្រុមស្នូលតូចមួយបានធ្វើការនៅឆ្នាំ២០០៥ និង ២០០៦ ដើម្បីពិគ្រោះយោបល់ នឹងកសាងនីតិវិធីជាដំបូងៗ ព្រមទាំងបញ្ជីសំណួរស្តង់ដារមួយ សម្រាប់ធ្វើការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រនៅតាមតំបន់ជនបទ (គេមិនទាន់ផ្តល់អាទិភាពឱ្យតំបន់ទីក្រុង នៅឡើយទេ) ។

ដើម្បីទទួលបាននូវជំនួយគាំទ្រក្នុងរយៈពេលមធ្យមសម្រាប់ការរៀបចំ និងការអនុវត្តឧបករណ៍ស្តង់ដារ ក្រសួងផែនការបានស្នើសុំជំនួយហិរញ្ញវត្ថុ និងបច្ចេកទេស បន្ថែមពីរដ្ឋាភិបាលអាល្លឺម៉ង់ ។ រដ្ឋាភិបាលអាល្លឺម៉ង់បានផ្តល់ជំនួយនេះ នៅដើមឆ្នាំ២០០៦ ដោយជួលឱ្យ GTZ នៅកម្ពុជា ជួយដល់ក្រសួងផែនការតាមរយៈកម្មវិធី "ការគាំទ្រដល់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ" (IDPoor) ។ ការគាំទ្រនេះចាប់ផ្តើមនៅខែមេសា ២០០៦ ហើយដំណាក់កាលបច្ចុប្បន្ន នឹងចប់សព្វគ្រប់នៅដំណាច់ឆ្នាំ២០០៩ ។

## គោលដៅ

គោលដៅធំនៃកម្មវិធីរបស់ក្រសួងផែនការ គឺការប្រកាសទទួលស្គាល់ជាផ្លូវការនូវនីតិវិធីស្តង់ដារ ដើម្បីធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងបង្កើនការប្រើប្រាស់នីតិវិធីនេះឱ្យបានទូលំទូលាយ ក្នុងប្រទេសកម្ពុជា ។ ចំណុចសំខាន់មួយនៅក្នុងនេះ គឺត្រូវបញ្ចូលអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ជាការងារប្រចាំរបស់ក្រុមប្រឹក្សាឃុំ និងអង្គភាពនានាដែលជួយទ្រទ្រង់ឃុំ (ឧ. អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត-ក្រុង និងក្រុមសំរបសំរួលថ្នាក់ខេត្ត និងស្រុក) ។

គោលដៅសំខាន់មួយទៀតនៃកម្មវិធី គឺជំរុញការប្រើប្រាស់ជាទូទៅនូវទិន្នន័យប្រមូលបាន ដោយស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល គំរោង/កម្មវិធីតាមវិស័យនានា និងក្រុមប្រឹក្សាឃុំ នៅក្នុងការងារកំណត់មុខសញ្ញា និងផ្តល់សេវានិងជំនួយដល់គ្រួសារក្រីក្រ ។

## អ្វីទៅជាអត្តសញ្ញាណកម្មគ្រួសារក្រីក្រ? តើដើម្បីអ្វី?

យោងទៅលើនីតិវិធីដែលប្រើដោយក្រសួងផែនការនិងអង្គការដៃគូ អត្តសញ្ញាណកម្មគ្រួសារក្រីក្រ គឺជាការរកឱ្យឃើញគ្រួសារក្រីក្រ និងកំរិតភាពក្រីក្ររបស់គ្រួសារនីមួយៗដែលរស់នៅតំបន់ជនបទ ។ តាមវិធីនេះ ឈ្មោះនិង អាស័យដ្ឋាននៃគ្រួសារក្រីក្ររួមទាំងសមាជិកនីមួយៗត្រូវប្រមូល ។ គោលបំណងនៃការកំណត់អត្តសញ្ញាញគ្រួសារនីមួយៗនេះ គឺដើម្បីកំណត់គោលដៅសម្រាប់ផ្តល់សេវា និងជំនួយអភិវឌ្ឍន៍ ឱ្យចំគ្រួសារដែលក្រីក្រជាងគេនៅតាមភូមិ ដើម្បីជួយលើកស្ទួយពួកគេឱ្យចាកផុតពីភាពក្រីក្រ ព្រមទាំងការពារពួកគេឱ្យផុតពីគ្រោះថ្នាក់នានា (ដូចជា មានជម្ងឺធ្ងន់ធ្ងរ ការខូចខាតផលដំណាំ) ដែលធ្វើឱ្យពួកគេកាន់តែក្រីក្រខ្លាំងឡើង ។

ទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក៏អាចប្រើផងដែរសម្រាប់គណនាកំរិតភាពក្រីក្រប្រៀបធៀប របស់ភូមិនានា ដោយផ្អែកលើចំនួនគ្រួសារក្នុងចំណាត់ថ្នាក់ភាពក្រីក្រទាំងពីរប្រភេទតាមភូមិនីមួយៗ ។ អ្នកផ្តល់សេវា អាចប្រើទិន្នន័យនេះ ដើម្បីកំណត់ឃុំ ឬភូមិដែលក្រីក្រជាងគេ និងគ្រួសារក្រីក្រនៅក្នុងតំបន់ទាំងនោះ ។

នៅកម្ពុជា ទិន្នន័យអំពីគ្រួសារក្រីក្រ អាចប្រើបានច្រើនយ៉ាង ដូចជាការផ្តល់សេវាព្យាបាលសុខភាព ដោយឥតគិតថ្លៃ រឺដោយចុះថ្លៃ (ឧ. តាមរយៈមូលនិធិសមធម៌សុខភាព រឺការធានារ៉ាប់រងសុខភាពសង្គម) អាហារូបករណ៍ ឬជំនួយហិរញ្ញវត្ថុ ដល់សិស្សក្រីក្រ សេវាអភិវឌ្ឍន៍ជនបទនិងវិស័យកសិកម្ម ការបែងចែកដីសម្បទានសង្គមកិច្ចដល់គ្រួសារក្រីក្រ និងការប្រើប្រាស់ផ្សេងៗទៀត ហើយទិន្នន័យនេះ ក៏មានសក្តានុពលសំរាប់ប្រើប្រាស់ក្នុងការកសាងកម្មវិធីផ្ទេរសាច់ប្រាក់ ដោយមានលក្ខខណ្ឌ រឺគ្មានលក្ខខណ្ឌផ្សេងៗ ។

## តើអត្តសញ្ញាណកម្មគ្រួសារក្រីក្រកំពុងអនុវត្តនៅកន្លែងណា?

នៅឆ្នាំ២០០៧ ក្រសួងផែនការ ដោយរួមសហការជាមួយក្រសួងមហាផ្ទៃ បានអនុវត្តសាកល្បងជាទ្រង់ទ្រាយតូច នូវគំរូដំបូងនៃនីតិវិធី និងបញ្ជីសំណួរ បន្ទាប់មកបានធ្វើការកែសំរួល ហើយអនុវត្តនីតិវិធីជាទ្រង់ទ្រាយធំនៅខេត្តក្រចេះ (ខេត្តទាំងមូល) និង សៀមរាប (ស្រុកប្រតិបត្តិ (OD) សូទ្រនិគមនិងក្រឡាញ់) ។ នៅឆ្នាំ២០០៨ បានអនុវត្ត ពង្រីកទៅខេត្តឧត្តរមានជ័យទាំងមូល, ទៅ OD បី នៅខេត្តកំពង់ចាម គឺជើងព្រៃ/បាធាយ, ចំការលើ/ស្ទឹងត្រង់,

---

* Julian Hansen ជាប្រធានក្រុមនៃកម្មវិធី "ការគាំទ្រដល់កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ" របស់អង្គការសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ ដែលមានទីតាំងនៅក្នុងក្រសួងផែនការ ។ ចំពោះព័ត៌មានបន្ថែមទាក់ទិននឹងកម្មវិធីនេះ សូមទាក់ទងៈ

**លោក ជា ចាន់ទុំ** អ្នកសំរបសំរួលគំរោងនៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក្រសួងផែនការ ។ ទូរស័ព្ទៈ ០១២ ៨៦៧ ៨៦៧/០២៣ ២២០ ៧៤០ អ៊ីមែលៈ idpoor@online.com.kh ឬ chantum@mop.gov.kh ។

ឬ **លោក Julian Hansen** ទូរស័ព្ទៈ ០១២ ៤៧៦ ៩៩៥/០២៣ ២២០ ៧៤០ អ៊ីមែលៈ julian.hansen@gtz.org.kh ។

និងព្រៃឈរ/កងមាស និង OD ពីរ នៅខេត្តព្រៃវែង គឺពារាំង និង ព្រះស្តេច ។ ដូច្នេះមកដល់ខែកក្កដា ២០០៨ ក្រសួងផែនការបានកំណត់គ្រួសារក្រីក្រ ដោយប្រើនីតិវិធីថ្នាក់ជាតិ ក្នុង ៥ខេត្ត (ខេត្តទាំងមូល រឺមួយភាគ) រឺត្រូវជា ២១២៨ភូមិ ។

ក្នុងដើមឆ្នាំ២០០៩ ក្រសួងផែនការ អាចនឹងធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅស្រុកប្រតិបត្តិចំនួនពីរទៀត ក្នុងខេត្តកំពង់ចាម (មេមត់ និងពញាក្រែក) និង ខេត្តកំពង់ធំ និងកំពត ។ ក្រសួងកំពុងតែពិចារណាតំបន់ផ្សេងទៀត ដើម្បីអនុវត្តប្រសិនបើមានថវិកាគ្រប់គ្រាន់ ។

ព័ត៌មានត្រឡប់ ត្រូវបានប្រមូលតាមរយៈអ្នកអនុវត្តនិងអ្នកពាក់ព័ន្ធដំណើរការ ដើម្បីធ្វើការកែលំអនីតិវិធីនិង ការអនុវត្តរបស់ពួកគេ ។ម្យ៉ាងទៀត មានការពិគ្រោះយោបល់ជាប្រចាំជាមួយ ក្រុមការងារស្នូលថ្នាក់ជាតិ និងក្រុមការងារ ដើម្បីតំរង់ទិសយុទ្ធសាស្ត្រ និងកសាងគោលនយោបាយថែមទៀត ។

ជាបន្ថែមលើ ៥ខេត្ត ដែលក្រសួងផែនការបានអនុវត្តនីតិវិធីក្នុងខេត្តទាំងមូល ឬមួយភាគ ពួកអ្នកប្រើមូលនិធិសមធម៌ថែទាំសុខភាព និងដៃគូនានាក៏បានប្រើនីតិវិធីនេះក្នុងតំបន់មួយចំនួនទៀតដែរ ។ នៅឆ្នាំ២០០៧ និង ២០០៨ HSSC (គំរោងពង្រឹងប្រព័ន្ធសុខាភិបាលនៅកម្ពុជា) អនុវត្តដោយ University Research Company (URC) បានអនុវត្តនីតិវិធីថ្នាក់ជាតិនេះក្នុង ប្រាំ OD នៅខេត្តបន្ទាយមានជ័យ បាត់ដំបង និង ពោធិសាត់។ ក្នុងរយៈពេលនេះដែរ សមាគមអង្គការមិនមែនរដ្ឋាភិបាលខាងសុខភាពបន្តពូជនៅកម្ពុជា បានអនុវត្តនីតិវិធីនេះ ក្នុងប្រាំ ODs នៅ ក្រុងព្រះសីហនុ ខេត្តកំពង់ឆ្នាំង និង កំពង់ចាម ។ គំរោង HSSC ក៏មានគំរោងអនុវត្តនៅ ខេត្តរតនគិរី មណ្ឌលគិរី និងកោះកុង (ODs ស្រែអំបិល និងស្មាច់មានជ័យ) នៅចុងឆ្នាំ២០០៨ និងដើមឆ្នាំ២០០៩ ។

តំបន់ទាំងអស់ដែលក្រសួងផែនការ និងអង្គការដៃគូបានអនុវត្តនីតិវិធីសុទ្ធតែជាកន្លែងដែលមានមូលនិធិសមធម៌សុខភាពកំពុងដំណើរការ ។ តំបន់ជាច្រើនក៏មានអ្នកផ្តល់សេវាប្រភេទផ្សេងទៀតច្រើនគួរសមដែរ ។ ក្រសួងផែនការយល់ថា គួរជ្រើសរើសជាសំខាន់នូវតំបន់នានាដែលមានសេវាច្រើនគ្រប់គ្រាន់ដើម្បីឱ្យសមនឹងការប្រឹងប្រែង និងបន្ទុកចំណាយលើការស្រាវជ្រាវ ព្រមទាំងមានលទ្ធភាពខ្ពស់ថា បណ្តាសហគមន៍ និងអាជ្ញាធរមូលដ្ឋាន នឹងទទួលស្គាល់ផលប្រយោជន៍នៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ។

## តើអត្តសញ្ញាណកម្មគ្រួសារក្រីក្រត្រូវអនុវត្តយ៉ាងដូចម្តេច?

ដំណើរការអត្តសញ្ញាណកម្មក្នុងភូមិនីមួយៗ ត្រូវធ្វើឡើងដោយក្រុមតំណាងភូមិ (ក.ត.ភ) ដោយមានការគាំទ្រ និងត្រួតពិនិត្យពីក្រុមតំណាងគណៈកម្មាធិការកសាងផែនការនិងថវិកា ក្រុមប្រឹក្សាឃុំ និង អ្នកតំណាងមកពីក្រុមសំរបសំរួលស្រុក ។ ដំណើរការនេះសម្របសម្រួលដោយមន្ទីរផែនការខេត្ត ដោយរួមសហការជាមួយអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត។ ក្រសួងផែនការទទួលបន្ទុកផ្តល់ការបណ្តុះបណ្តាលថ្នាក់ខេត្ត ពិនិត្យតាមដានការអនុវត្ត និងផ្តល់ជំនួយគាំទ្របច្ចេកទេសជាប្រចាំ ។

ការងារអនុវត្តពឹងផ្អែកលើវិធីសាស្ត្រធ្វើការបណ្តុះបណ្តាលច្រើនដំណាក់។ បុគ្គលិកក្រសួងថ្នាក់ជាតិ បណ្តុះបណ្តាលសមាជិកនៃក្រុមសម្របសម្រួលថ្នាក់ខេត្ត និងក្រុមសម្របសម្រួលថ្នាក់ស្រុក ឱ្យក្លាយជាអ្នកបណ្តុះបណ្តាល ព្រមទាំងផ្តល់ជំនួយគាំទ្រដើម្បីឱ្យពួកគេអាចបណ្តុះបណ្តាលក្រុមប្រឹក្សាឃុំ ក្រុមតំណាងគណៈកម្មាធិការកសាងផែនការនិងថវិកា ក្រុមតំណាងភូមិ និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ។

អត្តសញ្ញាណកម្មគ្រួសារក្រីក្រមាន ៧ជំហាន ដែលមានពិពណ៌នាលំអិតក្នុងឯកសារ *សៀវភៅណែនាំស្តីពីនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រី* (ដែលមានចុះក្នុងវេបសាយ www.mop.gov.kh/ProgramsProjects/IDPoor/tabid/154/Default.aspx) និង មានសេចក្តីសង្ខេបដូចតទៅ:

ជំហាន១: បង្កើត និងបណ្តុះបណ្តាល ក្រុមតំណាងគណៈកម្មាធិការកសាងផែនការនិងថវិកា (ក្រុមតំណាង គ.ផ.ថ)
- រៀបចំប្រជុំគណៈកម្មាធិការកសាងផែនការនិងថវិកា ដើម្បីជ្រើសរើសក្រុមតំណាង គ.ផ.ថ
- បណ្តុះបណ្តាលសមាជិកក្រុមតំណាង គ.ផ.ថ
- បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ឃុំ

ជំហាន២: ជ្រើសរើស និងបណ្តុះបណ្តាលក្រុមតំណាងភូមិនានា
- រៀបចំកិច្ចប្រជុំភូមិលើកដំបូង ដើម្បីជ្រើសរើសសមាជិកក្រុមតំណាងភូមិ
- គ្រូបង្គោលថ្នាក់ឃុំ បណ្តុះបណ្តាលក្រុមតំណាងភូមិ និងរៀបចំការសំភាសន៍សាកល្បង

ជំហាន៣: ក្រុមតំណាងភូមិ ចងក្រងបញ្ជីគ្រួសារក្នុងភូមិ សំភាសន៍គ្រួសារ និងចងក្រងបញ្ជីព្រាងគ្រួសារក្រីក្រលើកដំបូង ចងក្រងបញ្ជីឈ្មោះគ្រួសារក្នុងភូមិ
- ចងក្រងបញ្ជីគ្រួសារក្នុងភូមិសម្រាប់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ
- សំភាសន៍គ្រួសារ
- បូកសរុបពិន្ទុ និងរៀបចំបញ្ជីព្រាងចំណាត់ថ្នាក់គ្រួសារក្រីក្រ
- ពិភាក្សាក្នុងក្រុមតំណាងភូមិអំពីស្ថានភាពគ្រួសារ និងកែសម្រួលចំណាត់ថ្នាក់ភាពក្រីក្ររបស់គ្រួសារមួយចំនួនតាមការចាំបាច់
- រៀបចំកិច្ចប្រជុំថ្នាក់ឃុំ ដើម្បីត្រួតពិនិត្យបញ្ជីព្រាងចំណាត់ថ្នាក់គ្រួសារក្រីក្រ
- រៀបចំបញ្ជីព្រាងគ្រួសារក្រីក្រលើកដំបូង

ជំហាន៤: រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ក្នុងភូមិស្តីពីបញ្ជីព្រាងគ្រួសារក្រីក្រលើកដំបូង ការទទួលមតិជំទាស់របស់អ្នកភូមិ និងការរៀបចំបញ្ជីព្រាងគ្រួសារក្រីក្រចុងក្រោយ
- បិទផ្សាយជាសាធារណៈនៅក្នុងភូមិ នូវបញ្ជីព្រាងគ្រួសារក្រីក្រលើកដំបូង
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ក្នុងភូមិ
- ទទួលមតិជំទាស់របស់អ្នកភូមិ
- រៀបចំបញ្ជីព្រាងគ្រួសារក្រីក្រចុងក្រោយ និងបញ្ជូនទៅក្រុមប្រឹក្សាឃុំ

ជំហាន ៥: ការត្រួតពិនិត្យឡើងវិញ និងអនុម័តបញ្ជីគ្រួសារក្រីក្រចុងក្រោយដោយក្រុមប្រឹក្សាឃុំ និងការរៀបចំ ប័ណ្ណសមធម៌
- ក្រុមប្រឹក្សាឃុំត្រួតពិនិត្យឡើងវិញនូវ បញ្ជីគ្រួសារក្រីក្រចុងក្រោយរបស់ភូមិនីមួយៗនិងសម្របសម្រួលដោះស្រាយរាល់មតិជំទាស់ ឬសំណូមពររបស់អ្នកភូមិ
- ក្រុមប្រឹក្សាឃុំ អនុម័តទទួលស្គាល់បញ្ជីគ្រួសារក្រីក្រចុងក្រោយ ដែលរៀបចំដោយក្រុមតំណាងភូមិ
- ក្រុមប្រឹក្សាឃុំ បញ្ជូនទៅមន្ទីរផែនការខេត្ត នូវបញ្ជីគ្រួសារក្នុងភូមិ បញ្ជីគ្រួសារក្រីក្រចុងក្រោយ បញ្ជីសំណួរ និងសេចក្តីបញ្ជាក់របស់ក្រុមប្រឹក្សាឃុំស្តីពី ការអនុម័តទទួលស្គាល់បញ្ជីគ្រួសារក្រីក្រចុងក្រោយ
- ប្រធានក្រុមប្រឹក្សាឃុំចុះហត្ថលេខា និងបោះត្រាឃុំលើប័ណ្ណសមធម៌ រួចហើយប្រគល់ឱ្យក្រុមតំណាងភូមិ ដើម្បី ចែកឱ្យគ្រួសារក្រីក្រ (ក្រោយពីការបញ្ចូលទិន្នន័យ និងការថតរូបក្នុងជំហាន ៦ និង ៧)

ជំហាន ៦: មន្ទីរផែនការខេត្ត បញ្ចូលបញ្ជីគ្រួសារក្នុងភូមិ បញ្ជីគ្រួសារក្រីក្រចុងក្រោយ បញ្ជីសំណួរ រូបថតគ្រួសារក្រីក្រ និងតារាងតាមដានការថតរូបចូលក្នុងទិន្នន័យមូលដ្ឋាន គ្រួសារក្រីក្រ

ជំហាន ៧: ការថតរូបគ្រួសារក្រីក្រ
- ក្រុមថតរូបថតគ្រួសារក្រីក្រ

- មន្ទីរផែនការខេត្តបញ្ចូលទិន្នន័យទៅក្នុងទិន្នន័យមូលដ្ឋានគ្រួសារក្រីក្រ
- ការបោះពុម្ពប័ណ្ណសមធម៌ មន្ទីរផែនការខេត្តចែកចាយដល់ក្រុមប្រឹក្សាឃុំ

ដំណើរការខាងលើមានការពិគ្រោះយោបល់ និងចូលរួមពីអ្នកភូមិយ៉ាងច្រើន: អ្នកភូមិបោះឆ្នោតជ្រើសរើសក្រុមតំណាងភូមិ ហើយអ្នកភូមិមួយចំនួនបានក្លាយជាសមាជិកក្រុមតំណាងភូមិ ដើម្បីទទួលខុសត្រូវសំភាសន៍ ។ អ្នកភូមិចូលរួម ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ក្នុងភូមិស្តីពីបញ្ជីគ្រួសារក្រីក្រលើកដំបូង ដើម្បីលើកនូវសំណូមពរឬមតិជំទាស់ដែលពាក់ព័ន្ធទៅនឹង បញ្ជីព្រាងគ្រួសារក្រីក្រលើកដំបូង និងបញ្ជីព្រាងគ្រួសារក្រីក្រចុងក្រោយ ។

សមិទ្ធផលនៃដំណើរការនៅថ្នាក់ឃុំនិងភូមិ គឺបញ្ជីគ្រួសារក្រីក្រចុងក្រោយក្នុងភូមិនីមួយៗ ។ ម្យ៉ាងទៀត អាស្រ័យលើតម្រូវការជាក់ស្តែង គ្រួសារដែលបានកំណត់ថាជាគ្រួសារក្រីក្រ គឺអាចទទួលបានប័ណ្ណសមធម៌ ។ ប័ណ្ណនេះបង្ហាញនូវព័ត៌មានមួយចំនួនដូចជា ឈ្មោះភូមិ ឃុំ ស្រុក និងខេត្ត, ឈ្មោះ ភេទ និងឆ្នាំកំណើតរបស់មេគ្រួសារ កំរិតភាពក្រីក្រ និងរូបថតគ្រួសារ ។ ប័ណ្ណនេះ ១) បញ្ជាក់ឱ្យគ្រួសារក្រីក្រដឹងថា ពួកគេអាចស្វែងរកសេវា ឬជំនួយផ្សេងៗដែលពួកគេមានសិទ្ធិនឹងទទួល ២) ជួយសម្រួលដល់អ្នកផ្តល់សេវាក្នុងការបញ្ជាក់ពីអត្តសញ្ញាណនៃសមាជិកគ្រួសារក្រីក្របានឆាប់រហ័សដើម្បីផ្តល់សេវាដល់ពួកគេ ។ បញ្ជីគ្រួសារក្រីក្រ ត្រូវបានធ្វើបច្ចុប្បន្នភាពពីរឆ្នាំម្តងដើម្បីរក្សានូវភាពសុក្រិត ។

## បញ្ជីសំណួរ

បច្ចុប្បន្នបញ្ជីសំណួរស្តង់ដារជាតិ ត្រូវបានប្រើប្រាស់នូវគ្រប់តំបន់ដែលអនុវត្តដោយក្រសួងផែនការ ឬអង្គការដៃគូ ដើម្បីសម្រេចឱ្យបាននូវលទ្ធផលមួយដែលអាចប្រៀបធៀបគ្នាបានក្នុងចំណោមគ្រួសារ និងតំបន់ភូមិសាស្ត្រផ្សេងគ្នា (ភូមិ ឃុំ ស្រុក ខេត្ត) ។ បញ្ជីសំណួរមានសូចនាករសាមញ្ញធម្មតាៗមួយចំនួនដែលក្រុមការងារថ្នាក់ជាតិស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ បានឯកភាពគ្នាទទួលស្គាល់ថា អាចវាស់វែងភាពក្រីក្របានសមស្រប ។ សូចនាករទាំងនេះផ្អែកជាសំខាន់ទៅលើទ្រព្យសម្បត្តិ ដែលអាចសង្កេតមើលឃើញនិងងាយផ្ទៀងផ្ទាត់បាន ប៉ុន្តែក៏រួមបញ្ចូលផងដែរនូវបញ្ហាដទៃទៀតដូចជា អត្រាសមាជិកគ្រួសារដែលមិនអាចរកចំណូល ការខកខានរៀន វិបត្តិឬបញ្ហាចៃដន្យ និងស្ថានភាពពិសេសផ្សេងទៀតដែលធ្វើឱ្យពួកគេងាយរងគ្រោះ ។ ការសំភាសន៍ត្រូវបានធ្វើ ដោយក្រុមតំណាងភូមិដែលមាន ការយល់ដឹងច្បាស់លាស់ពីស្ថានភាពនៅមូលដ្ឋានដែលធ្វើឱ្យងាយស្រួលបញ្ជាក់ថា អ្នកផ្តល់ចម្លើយបានឆ្លើយត្រឹមត្រូវ ស្របតាមស្ថានភាពជាក់ស្តែងរបស់ពួកគេដែរឬទេ ។ ម្យ៉ាងទៀត សមាជិកក្រុមតំណាងភូមិអាចដឹងអំពីស្ថានភាពពិសេស របស់គ្រួសារដែលរស់នៅក្នុងភូមិរបស់គាត់ ។

បញ្ជីសំណួរមានសំនួរដាក់ពិន្ទុ និងសំណួរមិនដាក់ពិន្ទុ ។ សំណួរមានពិន្ទុទាំងនោះគឺជាមូលដ្ឋានចម្បងដើម្បីដាក់ចំណាត់ថ្នាក់ភាពក្រីក្រដល់គ្រួសារ ឬមិនបញ្ចូលពួកគេក្នុងបញ្ជីគ្រួសារក្រីក្រ ។ សំណួរនីមួយៗមានទម្ងន់ពិន្ទុខុសៗគ្នា អាស្រ័យទៅលើកម្រិតទំនាក់ទំនងជាមួយនឹងភាពក្រីក្រ ។ ទម្ងន់ទាំងនេះមិនត្រូវបានគណនាតាមបែបវិទ្យាសាស្ត្រទេ ប៉ុន្តែត្រូវបានសម្រេចដោយក្រុមការងារថ្នាក់ជាតិផ្អែកលើបទពិសោធន៍នៅមូលដ្ឋាន ។ ខ្លឹមសារនៃសំណួរទាំងនេះ ត្រូវបានសង្ខេបដូចខាងក្រោម:

- ស្ថានភាពផ្ទះ: ដំបូល ជញ្ជាំង ផ្ទៃក្រឡា និងស្ថានភាពទូទៅនៃផ្ទះ
- ទំហំផ្ទៃដីធ្វើស្រែចំការ គិតជាហិកតា ឬ ឧបករណ៍នេសាទ ឬប្រភពចំណូលផ្សេងទៀតដូចជា ប្រាក់ឈ្នួល ប្រាក់បៀវត្ស ឬការធ្វើអាជីវកម្ម
- ការចិញ្ចឹមសត្វ (រួមទាំងការចិញ្ចឹមត្រីដើម្បីលក់)
- ការខ្វះបុលស្រូវ (បញ្ជាក់ពីភាពមានលទ្ធភាព ឬ គ្មានលទ្ធភាពបំពេញតម្រូវការស្បៀងអាហារ)
- សមាមាត្រសមាជិកដែលមិនអាចរកប្រាក់ចំណូលបាន
- ទ្រព្យសម្បត្តិ (ជាពិសេសឧបករណ៍អេឡិចត្រូនិក)
- មធ្យោបាយធ្វើដំណើរ (រួមទាំងទូក សំរាប់ភូមិបណ្តែតទឹក)

ក្នុងបញ្ជីសំណួរ ក៏មានសំណួរមួយចំនួនមិនដាក់ពិន្ទុដែរ (ពាក់ព័ន្ធបញ្ហាមួយចំនួនដែលពិបាកកំណត់ពិន្ទុ) សម្រាប់សមាជិកក្រុមតំណាងភូមិពិភាក្សា និងពិចារណាលើផលប៉ះពាល់ដល់គ្រួសារក្រីក្រទាំងនោះ ។ ក្រុមតំណាងភូមិក៏ត្រូវយកចិត្តទុកដាក់ផងដែរលើព័ត៌មាន សំណូមពរ មតិជំទាស់ ដែលលើកឡើងដោយអ្នកភូមិក្នុងអំឡុងដំណើរការពិគ្រោះយោបល់ជាសាធារណៈ។ ព័ត៌មាននេះ អាចត្រូវបានប្រើប្រាស់ដោយក្រុមតំណាងភូមិដើម្បីកែសម្រួលចំណាត់ថ្នាក់ភាពក្រីក្ររបស់គ្រួសារ ។ បញ្ជីសំណួរមិនដាក់ពិន្ទុ គ្របដណ្តប់បញ្ហាដូចខាងក្រោម:

- បញ្ហាឬវិបត្តិចៃដន្យដែលបណ្តាលអោយគ្រួសារបាត់បង់ប្រាក់ចំណូល ខ្វះស្បៀងអាហារ លក់ទ្រព្យសម្បត្តិ ឬខ្ចីលុយគេក្នុងរយៈពេល១២ខែកន្លងមក
- ចំនួនក្មេងអាយុ៦-១១ឆ្នាំ ដែលមិនបានចូលរៀននិងខកខានរៀនអស់រយៈពេលយ៉ាងតិច១ខែនៅក្នុងអំឡុង ពេល១២ខែ កន្លងមក
- ស្ថានភាពពិសេសរបស់គ្រួសារ (ពិការភាព ជំងឺ ចាស់ជរា ស្ត្រីមេម៉ាយដែលមានកូនតូចៗច្រើន គ្មានមនុស្សពេញវ័យ ឬស្ថានភាពដទៃទៀត)

ចំពោះព័ត៌មានលំអិតអំពីបញ្ជីសំណួរ សូមមើលវែបសាយ www.mop.gov.kh/ProgramsProjects/IDPoor/tabid/154/Default.aspx ។

## ចំណាត់ថ្នាក់ភាពក្រីក្រ

មានចំណាត់ថ្នាក់ភាពក្រីក្រពីរ សម្រាប់ដាក់ឱ្យគ្រួសារក្រីក្រ: ក្រកំរិតទី១ (ក្រីក្របំផុត) ឬក្រកំរិតទី២ (ក្រីក្រ) ។ ចំណាត់ថ្នាក់ភាពក្រីក្រទាំងនេះត្រូវបានកំណត់ដោយផ្អែកលើពិន្ទុក្នុងបញ្ជីសំណួរ (ដោយយោងតាមចន្លោះ ពិន្ទុដែលបានកំណត់) និងការពិចារណាលើស្ថានភាពពិសេសរបស់គ្រួសារនោះ ។ សមាមាត្រគ្រួសារដែលស្ថិតក្នុងចំណាត់ថ្នាក់ភាពក្រីក្រទាំងពីរ ត្រូវបានក្រិតអោយស្របទៅនឹងលទ្ធផលនៃ អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៤ (ដែលមានការប្រែប្រួលខ្លះៗហើយ) ។ ក្រកំរិតទី១ មានសមាមាត្រប្រហាក់ប្រហែលនឹង សមាមាត្រគ្រួសារដែលស្ថិតក្រោមខ្សែបន្ទាត់ភាពក្រីក្រផ្អែកម្ហូបអាហារដែលកំណត់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា រីឯក្រកំរិតទី២ ក៏មានសមាមាត្រប្រហាក់ប្រហែលនឹង គ្រួសារដែលស្ថិតក្នុងចន្លោះរវាងខ្សែបន្ទាត់ភាពក្រីក្រផ្អែកម្ហូបអាហារ និងខ្សែបន្ទាត់ភាពក្រីក្រដែលកំណត់ដោយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច កម្ពុជា ។ ជាមធ្យម មានប្រហែលមួយភាគបីនៃគ្រួសារសរុបត្រូវបានដាក់ក្នុងចំណាត់ថ្នាក់ក្រកំរិតទី១ ឬ ក្រកំរិតទី២ រួចបញ្ចូលទៅក្នុងបញ្ជីគ្រួសារក្រីក្រ ។

## ចំណុចខ្លាំង និងកំហិតនៃវិធីសាស្ត្រ

កម្មវិធីផ្តោតជាសំខាន់ទៅលើ ការប្រើប្រាស់នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីពង្រីកវិសាលភាពនៃការអនុវត្តដោយរចនាសម្ព័ន្ធរដ្ឋាភិបាលនិងតំណាងភូមិ ដើម្បីកសាងសមត្ថភាពនៅមូលដ្ឋាននិងជំរុញការអនុវត្តអោយមាននិរន្តរភាព ។ ប៉ុន្តែ ការសង្កត់ធ្ងន់លើការកសាងសមត្ថភាពនេះតម្រូវឱ្យមានការបណ្តុះបណ្តាលច្រើនគួរឱ្យកត់សម្គាល់ដែលបង្កើនការចំណាយ ។

នីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ មានការចូលរួមយ៉ាងខ្លាំងក្លាដោយអ្នកភូមិ ក៏ដូចជាការពិគ្រោះយោបល់រវាងអ្នកភូមិផ្ទាល់ ។ ការចូលរួមនេះ

បង្កើនតម្លាភាពនិងភាពត្រឹមត្រូវនៃលទ្ធផល ដែលធ្វើឱ្យអ្នកមូលដ្ឋាន និងអ្នកប្រើប្រាស់ទិន្នន័យងាយទទួលស្គាល់លទ្ធផល ។ ក៏ប៉ុន្តែ ការធ្វើដូច្នេះ បង្កើននូវភាពស្មុគស្មាញ និងពេលវេលាដែលត្រូវចំណាយខ្លះ ។

ផលវិជ្ជមានប្រយោលនៃដំណើរការនេះ គឺជាការពង្រឹងនូវលិទ្ធិប្រជាធិបតេយ្យក្នុងសហគមន៍ ដូចជា បង្កើននូវ ការគិតគូររបស់អ្នកដឹកនាំមូលដ្ឋានអំពីសុខមាលភាពប្រជាពលរដ្ឋ និងកំរិតនៃគណនេយ្យភាពចំពោះប្រជាពលរដ្ឋ, ការចូលរួមរបស់ប្រជាពលរដ្ឋយ៉ាងសកម្មក្នុងកិច្ចការសហគមន៍ និងបង្កើនការពិគ្រោះយោបល់និងតម្លាភាពក្នុងការធ្វើសេចក្ដីសម្រេចចិត្ត ។

ទោះបីជាការប្រើប្រាស់បញ្ជីសំណួរស្តង់ដារ មានសារៈសំខាន់ដើម្បីប្រៀបធៀបលទ្ធផលពីតំបន់មួយទៅតំបន់ផ្សេងទៀត ក៏អាចមានសំណួរខ្លះមិនអាចយកទៅប្រើប្រាស់នៅគ្រប់តំបន់ ឬជាមួយគ្រប់ជនជាតិ និងប្រភេទជីវភាព ។បញ្ហានេះអាចតម្រូវឱ្យធ្វើការកែសម្រួលបញ្ជីសំនួរតាមបទពិសោធន៍ដែលទទួលបានពីការអនុវត្ត ។

ចំពោះការប្រើប្រាស់បញ្ជីសំណួរ សមាជិកក្រុមតំណាងភូមិជួបប្រទះបញ្ហាស្មុគស្មាញខ្លះ ប៉ុន្តែដោយមានការបណ្តុះបណ្តាលនិងការណែនាំសមាជិកក្រុមតំណាងភូមិ ពួកគេមានសមត្ថភាពប្រើប្រាស់បញ្ជីសំណួរនេះ ។ ដោយសារតែមានសម្ពាធខ្លាំងពី សហគមន៍ដើម្បីបញ្ចូលគ្រួសារក្នុងបញ្ជីគ្រួសារក្រីក្រ ដូច្នេះ បញ្ជីសំណួរគឺជាឧបករណ៍ដ៏សំខាន់ដើម្បី បង្កើនភាពយុត្តិធម៌ក្នុង ការកំណត់កំរិតភាពក្រីក្រគ្រួសារ ។

## ទិន្នន័យមូលដ្ឋានគ្រួសារក្រីក្រ

ទិន្នន័យមូលដ្ឋានគ្រួសារក្រីក្រ ត្រូវបានរៀបចំដើម្បីគាំទ្រការអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងផលិតទិន្នន័យសម្រាប់អ្នកផ្តល់សេវា ។ ទិន្នន័យមូលដ្ឋាននេះត្រូវបានរៀបចំនៅកម្ពុជាហើយអាចប្រើបានជាពីរភាសា (ភាសាខ្មែរ និងអង់គ្លេស) ។ ទិន្នន័យមូលដ្ឋានត្រូវបានរៀបចំជាទម្រង់មួយដែលអនុញ្ញាតឱ្យមានការបញ្ចូលទិន្នន័យនៅតំបន់ផ្សេងៗគ្នាបាន បន្ទាប់មកអាចផ្តុំទិន្នន័យទាំងនោះនៅថ្នាក់ជាតិ ។ នៅក្នុងតំបន់ដែលគ្របដណ្តប់ដោយក្រសួងផែនការ មានមន្ទីរផែនការខេត្តទទួលខុសត្រូវបញ្ចូលទិន្នន័យ ។ ក្រសួងផែនការ ក៏ផ្តល់ទិន្នន័យមូលដ្ឋានដល់អង្គការដៃគូដើម្បីបញ្ចូលទិន្នន័យក្នុងតំបន់ដែលពួកគេគ្របដណ្តប់ ។ គោលបំណងរបស់ក្រសួងផែនការ គឺដើម្បីផ្តុំទិន្នន័យដែលបានមកពីតំបន់ដែលគ្របដណ្តប់ដោយក្រសួងផែនការក៏ដូចជា អង្គការដៃគូ ហើយទិន្នន័យទាំងនោះអាចចែករំលែកដល់អ្នកផ្តល់សេវាដើម្បី ធ្វើឱ្យមានប្រសិទ្ធភាពខ្ពស់ក្នុងការប្រមូលទិន្នន័យធៀបនឹងការចំណាយ ។

## ប្រភេទទិន្នន័យដែលមាន

កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រអាចផ្តល់នូវទិន្នន័យច្រើនប្រភេទសម្រាប់ស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល កម្មវិធីនិងគម្រោងតាមវិស័យ ដើម្បីប្រើប្រាស់សំរាប់ផ្តល់សេវា និងជំនួយដល់គ្រួសារក្រីក្រប្រកបដោយប្រសិទ្ធភាព ។ ទិន្នន័យទាំងនេះមានដូចជា:

- បញ្ជីគ្រួសារក្រីក្រច្បាប់ដើមសរសេរដោយដៃលើក្រដាស់ មានច្បាប់ចម្លងរក្សាទុកនៅភូមិ និងឃុំភ្លាមៗ បន្ទាប់ពីក្រុមប្រឹក្សាឃុំបានអនុម័តបញ្ជីគ្រួសារក្រីក្រ (មុនដំណើរការបញ្ចូលទិន្នន័យ) ។
- របាយការណ៍ចេញពីទិន្នន័យមូលដ្ឋានមានដូចជា:
  - បញ្ជីគ្រួសារក្រីក្រដែលមាននូវឈ្មោះ និងភេទមេគ្រួសារ ឈ្មោះប្ដីឬប្រពន្ធមេគ្រួសារ និងកំរិតភាពក្រីក្រ
  - ការពិពណ៌នាសង្ខេបអំពីសមាជិកគ្រួសារទាំងអស់ដែលមាន ឈ្មោះ ភេទ អាយុ ឆ្នាំកំណើត ទំនាក់ទំនងជាមួយមេគ្រួសារ នៃសមាជិកនីមួយៗ និងកំរិតភាពក្រីក្រ
  - របាយការណ៍ប្រៀបធៀបអត្រាក្រីក្រ: បង្ហាញនូវភាគរយសរុបនៃក្រកំរិតទី១ ក្រកំរិតទី២ និង គ្រួសារក្រីក្រក្នុងភូមិទាំងអស់ សំរាប់គ្រប់ភូមិក្នុងតំបន់គ្របដណ្តប់ ។ របាយការណ៍នេះ ក៏អាចវិភាគអត្រាភាពក្រីក្រធៀបទៅនឹងចំនួនប្រជាជន ។
  - ស្ថិតិសង្ខេបសម្រាប់តំបន់គ្របដណ្តប់: បង្ហាញនូវភាគរយមេធ្យាន នៃគ្រួសារក្រកំរិតទី១និងក្រកំរិតទី២ ភាគរយមេធ្យានសរុបនៃគ្រួសារក្រីក្រក្នុងភូមិ ភាគរយមេធ្យាននៃមនុស្សនៅក្នុង គ្រួសារក្រីក្រកំរិតទី១ និងក្រកំរិតទី២ ភាគរយមេធ្យាននៃអ្នកក្រីក្រសរុបក្នុងភូមិ និងភាគរយនៃគ្រួសារដែលមានមេគ្រួសារជាស្ត្រី និងជាបុរសដែលស្ថិតនៅក្នុងចំណាត់ថ្នាក់ភាពក្រីក្រនីមួយៗ ។
  - បញ្ជីឈ្មោះនិងរូបថតសមាជិកគ្រួសារក្រីក្រ: មានរូបថតគ្រួសារខ្នាតតូច កំរិតភាពក្រីក្រ ឈ្មោះ ភេទ និងឆ្នាំកំណើតនៃសមាជិកគ្រួសារទាំងអស់ ។ បញ្ជីនេះអាចបោះពុម្ពចេញជាទម្រង់ សៀវភៅដែលងាយស្រួលប្រើដោយអ្នកផ្តល់សេវានៅថ្នាក់មូលដ្ឋានដែលមិនមានលទ្ធភាពប្រើកុំព្យូទ័រ ។
- កម្មវិធីទិន្នន័យមូលដ្ឋានគ្រួសារក្រីក្រពេញ មានរូបថតគ្រួសារក្រីក្រនិងព័ត៌មានលម្អិតអំពីគ្រប់សមាជិកទាំងអស់ ហើយអាចបង្កើតរបាយការណ៍តាមការជ្រើសរើសប្រភេទទិន្នន័យដោយអ្នកប្រើប្រាស់ ។

## តំបន់ដែលមានទិន្នន័យ

បច្ចុប្បន្ន ក្រសួងផែនការមានទិន្នន័យពីជុំទី១នៃការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដែលបានអនុវត្តក្នុងឆមាសទីពីរ ឆ្នាំ២០០៧ នៅខេត្តក្រចេះទាំងមូល (ស្រុកប្រតិបត្តិឆ្លូង និងក្រចេះ) និងខេត្តសៀមរាប (ស្រុកប្រតិបត្តិ សូទ្រនិគម និងក្រឡាញ់) ។

ទិន្នន័យជុំទីពីរ ដែលបានមកពីការអនុវត្តក្នុងឆមាសទីមួយឆ្នាំ២០០៨ នឹងមានសំរាប់ចែកចាយនៅខែកញ្ញា ឬតុលា ឆ្នាំ២០០៨ ។ ទិន្នន័យនេះគ្របដណ្តប់ខេត្តសៀមរាប (ស្រុកប្រតិបត្តិអង្គរជុំនិងសៀមរាប) ខេត្តឧត្តរមានជ័យទាំងមូល ខេត្តកំពង់ចាម (ស្រុកប្រតិបត្តិជើងព្រៃ-បាធាយ, ចំការលើ-ស្ទឹងត្រង់, និងព្រៃឈរ-កងមាស) ខេត្តព្រៃវែង (ស្រុកប្រតិបត្តិពារាំង និងព្រះស្ដេច) ។

កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៃក្រសួងផែនការ នឹងខិតខំផ្តុំទិន្នន័យដែលប្រមូលដោយអង្គការដៃគូក្នុង ឆ្នាំ២០០៨ នៅក្នុងខេត្តកំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ និងកំពង់ចាម (ស្រុកប្រតិបត្តិដែលបានគ្របដណ្តប់) បន្ទាប់មកនឹងធ្វើការផ្សព្វផ្សាយទិន្នន័យទាំងនេះ ។ ក្នុងឆ្នាំ ២០០៩ នឹងមានទិន្នន័យគ្រួសារក្រីក្រនៃ ខេត្តរតនៈគីរី និងមណ្ឌលគីរី និង ស្រុកប្រតិបត្តិស្រែអំបិល និងស្មាច់មានជ័យខេត្តកោះកុង ។

## ទស្សនៈវិស័យ

បច្ចុប្បន្ន ធនធានរបស់ក្រសួងផែនការនៅមានកំរិត ដូច្នេះអាចប្រើប្រាស់សម្រាប់រៀបចំ អត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅក្នុងតំបន់គោលដៅមួយចំនួនក្នុងប្រទេសតែប៉ុណ្ណោះ ។ អាស្រ័យហេតុនេះក្រសួងផែនការ កំពុងសហប្រតិបត្តិការជាមួយអង្គការដៃគូដើម្បីគ្របដណ្តប់តំបន់ផ្សេងទៀត ជាពិសេសផ្តោត

*(តទៅទំព័រ ១៨)*